ការសំភាសន៍របស់អ៊ុំស្រី ព្រាប សូរិយា

ក៖ អ្នកធ្វើការសំភាសន៍ឈ្មោះ គង់ សីហា ខ៖ អ្នកត្រូវគេសំភាសន៍ឈ្មោះ ព្រាប សូរិយា

ក៖ បាទ! សូមជំរាបសួរអ៊ុំ នៅថ្ងៃនេះខ្ញុំពិតជាសប្បាយរីករាយខ្លាំងមែនទែន ដែលបានមកផ្ទះអ៊ុំ
ហើយអំពីជីវប្រវត្តិខ្លះរបស់អ៊ុំចឹងណា។ ហើយខ្ញុំដឹងថា អ្វីទាំងអស់នេះគឺជាពរជ័យ
សំរាប់ក្រុមគ្រួសាររបស់អ៊ុំ និងកូនចៅរបស់អ៊ុំនៅជំនាន់ក្រោយ
ជាពិសេសប្រជាជនកម្ពុជាផ្ទាល់តែម្តង។ ពួកគាត់អាចសិក្សាអំពីជីវប្រវត្តិរបស់អ៊ុំថា
តើអ៊ុំមានបានឆ្លងកាត់អ្វីខ្លះ? ភាពលំបាក? ភាពសប្បាយរីករាយ?
ឆ្លងកាត់នៅសម័យប៉ុលពតអ្វីខ្លះ? ហើយជាពិសេសកូនចៅរបស់អ៊ុំ អាចស្តាប់សំលេងរបស់អ៊ុំ
នៅថ្ងៃអនាគត ហើយកម្មវិធីត្រូវបានធ្វើឡើង ដោយសាលារៀនមួយនៅសហរដ្ឋអាមរិច
មានឈ្មោះថា BYU សាលារៀននឹងគឺជាសាលារៀនរបស់ព្រះវិហារសាសនាចក្រដែល។
ហើយភាគច្រើនកូនចៅយើងនឹង អាចចង់ទៅរៀននៅទីនោះគឺអាចទៅបាន
ចឹងណាអោយតែប្រលងតាមគេចឹងទៅ គឺយើងអាចទៅបានហើយ។ ហើយសំរាប់ខ្ញុំមានឈ្មោះថា
គង់ សីហាជាអ្នកការសំភាសន៍មួយនេះ ហើយថ្ងៃនេះគឺជាថ្ងៃទី៤ ខែ៦ ឆ្នាំ២០១៦
ធ្វើឡើងនៅផ្ទះរបស់អ៊ុំស្រី។ ចឹងសំរាប់អ៊ុំ តើអ៊ុំមានឈ្មោះអ្វីដែរ?

ខ៖ អ៊ុំមានឈ្មោះថា ព្រាប សូរិយា។

ក៖ ហើយអ៊ុំមានឈ្មោះហៅក្រៅទៀតទេ?

ខ៖ ឈ្មោះហៅក្រៅ គេហៅថាអ៊ុំម៉ម។

ក៖ ហើយសំរាប់អ៊ុំ រស់នៅទីនេះបានប៉ុន្មានឆ្នាំហើយដែរនៅផ្ទះនេះ?

ខ៖ អ៊ុំមករស់នៅទីកន្លែងនេះបាន ៨ឆ្នាំហើយ។

ក៖ ចឹងពីមុន អ៊ុំនៅទីកន្លែងណាវិញ?

ខ៖ អ៊ុំនៅនាគព័ន្ធ ឃុំអំពិលលើ ភូមិអំពិលលើ ស្រុកកំពង់សៀម។

ក៖ បាទ! អរគុណច្រើនអ៊ុំ ចឹងសំរាប់អ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរ?

ខ៖ ខ្ញុំកើតនៅឆ្នាំ១៩៥៥។

ក៖ ថ្ងៃ និងខែតើអ៊ុំនៅចាំដែរទេ?

ខ៖ ថ្ងៃទី៨ ខែ១០ ហើយឆ្នាំ១៩៥៥។

ក៖ អ៊ុំកើតនៅទីកន្លែងណាដែរ?

ខ៖ អ៊ុំកើតនៅខេត្តកំពង់ចាម។

ក៖ អ៊ុំអាចជួយប្រាប់ទីកន្លែងនេះបានដែរទេ?

ខ៖ នៅខេត្តកំពង់ចាម ភូមិមេម៉ាយបឹងកុក ជាស្រុកកំនើតបរស់ខ្ញុំ។

ក៖ ចឹងនៅទីនេះ អ៊ុំមានអាសយដ្ឋានអ្វីដែរ? ផ្ទះរបស់អ៊ុំរាល់ថ្ងៃ?

ខ៖ តំបន់នេះដូចជាទីរួមខេត្តដែល ស្រុកសំបូរមាស ខេត្តកំពង់ចាម។

ក៖ សំរាប់អ៊ុ ភាគច្រើននៅក្នុងស្រុកខ្មែរយើងគេច្រើនតែប្រើឆ្នាំជាសត្វ អ៊ុជាឆ្នាំសត្វអ្វីដែរ?

ខ៖ ខ្ញុំជាសត្វមមែ។

ក៖ សំរាប់អ៊ុ តើអ៊ុធ្លាប់ដែលបានរៀនភាសាបរទេសអ្វី ពីមុនមកដែរទេ?

ខ៖ អ៊ុអត់ដែលបានរៀនភាសាបរទេសទេ តែអ៊ុបានរៀនអក្សរខ្មែរ
ពីសង្គមលុននុលអ៊ុរៀនថ្នាក់ខ្លាស់សេរង់។ ថ្នាក់ខ្លាស់សេរង់ ដូចជាថ្នាក់ឌីភ្លូមឥលូវ
ដល់ពេលចប់សង្គ្រាមឆ្នាំ៧៩ អ៊ុចូលធ្វើការនៅប្រៃសណីយ៍ខេត្តកំពង់ចាម នៅកន្លែងទេឡេតម
អាតម។ ហើយអ៊ុបានធ្វើដំណើរទៅរៀននៅហូជីមីញ៣ឆ្នាំ រៀននៅភ្នំពេញ២ឆ្នាំ
ដល់ឆ្នាំ១៩៨៧អ៊ុមានណាឡែនអ៊ុក៏ឈប់ធ្វើការទៅ។

ក៖ ចឹងអ៊ុបានរៀនច្រើនណាស់ដែល។

ខ៖ កាលពីមុន អ៊ុចេះភាសាបារាំងច្រើន តែឥលូវភ្លេចអស់ហើយ អាចនិយាយមិនចេះតែម្តង
ពីព្រោះកាលណៅជំនាន់របស់អ៊ុ គឺគេចេះទាំងអស់គ្នា។

ក៖ ដូចម៉ាក់ខ្ញុំដែល កាលពីមុនគាត់បានរៀនភាសាបារាំងច្រើនដែល។

ខ៖ ចាំមើល កាលអ៊ុទៅរៀនសាធិរិការ នៅឆ្នាំ៧២។

ក៖ ចឹងសំរាប់អ៊ុ អ៊ុមានកូនហើយត្រូវដែរទេ?

ខ៖ ចាស!

ក៖ ខ្ញុំចង់សួរអំពីជីវិតអាពាហ៍ពិពាហ៍របស់អ៊ុវិញ អ៊ុអាចជួយប្រាប់បានដែរទេ?

ខ៖ ចាស! ជាមួយអ៊ុប្រុសគាត់អាយុបងអ៊ុ២៥ឆ្នាំ គ្រួសាររបស់អ៊ុបង អ៊ុ២៥ឆ្នាំ
២៤អាយុ៤៥ទើបបានរៀបការជាមួយគាត់។ អតីត គាត់ជាប្រធានអគ្គមនាគមខេត្តកំពង់ចាម
គាត់ធ្វើការងារនឹងតាំងពីឆ្នាំ៧៩មកម៉េច ដល់ឆ្នាំ៩០ក៏គាត់លាលែងពីតំណែងទៅ។

ក៖ ចឹងការដែលគាត់បានរៀបការជាមួយនឹងគាត់ តើឪពុកម្តាយរបស់អ៊ុមានបានដឹងឮដែរទេ?

ខ៖ ខ្ញុំឲ្យមានមង្គលការអីត្រឹមត្រូវចាស ម្តាយរបស់ខ្ញុំគាត់បានដឹងឮ
តែឪពុកខ្ញុំគាត់បានស្លាប់ទៅ ដោយសារគាត់អាយុបងខ្ញុំច្រើន។ គាត់អាយុ៨០ឆ្នាំជាងហើយ
បានតែម្តាយក្មេក។

ក៖ ចុះសំរាប់បណ្តាការអ្វី គាត់បានផ្តល់ខាងអ៊ុដែរទេ?

ខ៖ បណ្តាការគាត់បានអោយខ្ញុំ កាលនៅជំនាន់នោះបាន១នាលុយមាស
មិនដឹងជាស្មើប៉ុន្មានទេ។ ដឹងតែជាមាស ហើយអ៊ុបានរៀបការបន្ទាប់ពីចប់សង្គ្រាមវិញ
បន្ទាប់ពីឆ្នាំ៧៩នឹងតើ។ ពីព្រោះអីនៅជំនាន់ប៉ុលពត អ៊ុមានអាយុ១៨ឆ្នាំចេញមកវិញ
អ៊ុមានអាយុ២១ឆ្នាំ ដលើអាយុ២២ឆ្នាំទើបបានរៀបការ។ ចឹងការនៅជំនាន់នោះ
ការមុនដំបូងមានតែអង្ករមួយប៉ៅ មាស១នាគឺចប់ហើយ។

ក៖ ប៉ុណ្ណឹងច្រើនហើយណោះអ៊ុ?

ខ៖ ចាស! ប៉ុណ្ណឹងច្រើនកាលនៅជំនាន់នោះ។ កាលនោះមិនទាន់មានរូបថត
ទុកអោយកូនចៅទេ កាលនោះមិនទាន់មានទេ ទើបតែចប់សង្គ្រាមយើងមិនទាន់មានអីទេ។

ក៖ ចឹងនៅពេលដែលអ៊ុ បានជួបអ៊ុប្រុស ខ្ញុំចង់សួរតើអ៊ុអាចជួយប្រាប់ខ្ញុំបានទេ
អំពីរឿងនេះដោយសារកូនចៅ ពួកគាត់នឹងអាចស្តាប់? ដោយសារនៅពេលខ្លះ
គាត់អត់សូវមានពេលប្រាប់ពួកគាត់ទេ ចឹងពេលនេះគឺជាឱកាសទុកជាឯកសារសំរាប់ពួកគាត់។
សំរាប់ពួកគាត់ស្តាប់នៅថ្ងៃក្រោយចឹងណា ខ្ញុំសូមអ៊ុជួយប្រាប់អំពីមូលហេតុ
ដែលអ៊ុបានជួបនឹងអ៊ុប្រុស? ជួបគ្នានៅពេលណា? ហេតុអ្វីបានជាអ៊ុស្រលាញ់អ៊ុប្រុសដល់ថ្នាក់នឹង?

ខ៖ កាលនៅជំនាន់នោះ គាត់គឺជាប្រធានគមនាគមន៍ ហើយគាត់ក៏ជាប្រធានរបស់ខ្ញុំផងដែល
នៅក្នុងប្រៃសណីយ៏ដែលគេហៅថាជាសាខា។ ដល់ពេលយើងបានជួបគ្នា
នៅក្នុងការធ្វើការងារវិញ និយាយទៅថាយើងមានភាពជិតដិត
ដោយសារយើងធ្វើការជាមួយគ្នា។ ជំនាន់នោះ
និយាយអោយចំមិនទាន់មានយុវជនយុវនារីច្រើនទេ មកដល់ឥលូវមានគ្នាច្រើនទេ
គឺថាអត់ទេ។ ជំនាន់យើង ក្មេងសល់ពីប៉ុលពតនៅតិចណាស់ យើងអាចមើលគ្នា
ធ្វើអោយមានការជិតដិតជាមួយគ្នាកើត។ ពីព្រោះ យើងចេញពីប៉ុលពតមកគេហៅថា
ក្មេងចាស់ហើយ ឬក្រមុំចាស់ហើយអោយតែអាយុ២២, ២៣ឆ្នាំ។ ដល់ពេលចេញមក
យើងមើលឃើញតែគ្នាយើង ដល់ពួកក្មេងឥលូវទើបតែកើតមកក្នុងឆ្នាំ៨០ជាងទាំងអស់នេះ។

ក៖ ហើយអ៊ុធ្វើយ៉ងម៉េចខ្លះ បានជាអ៊ុដឹងថាអ៊ុប្រុសគាត់ចាប់អារម្មណ៍មកលើអ៊ុ?

ខ៖ នឹងគឺជាការស្និទស្នាគ្នា ដល់ការមានយកទឹកយកអីអោយគ្នាទៅវិញទៅមក នៅជាមួយគ្នា
ធ្វើការរួមគ្នា អង្គុយតុជិតគ្នា។ ហើយមានមនោសញ្ចេតនា ដូចថាមាននិស្សយចឹងទៅណាក្មួយ។

ក៖ នៅពេលនោះ អ៊ុប្រុសគាត់សួរថា គាត់ស្រលាញ់អ៊ុស្រី ឬមួយក៏គាត់និយាយអ្វីខ្លះដែរ?

ខ៖ ចង់និយាយថា ចុះបើយើងរៀបការនៅសម័យដែលចប់សង្គ្រាមហើយ
តើយើងអាចប្រើអង្ករតែ១ប៉ែបានអត់? ហើយខ្ញុំមានតែ១នា រៀបការឯងយកអត់? ហើយខ្ញុំថា
ធ្វើអីសម ក៏ធ្វើទៅ។ កាលអ៊ុរៀបការ គឺមិនទាន់មានសម្លៀកបំពាក់រៀបការទេ
នៅសល់កាក់សំណល់ខោខ្មៅ សំពត់ខ្មៅអីគឺស្លៀកធម្មតា។
ដោយសារតែយើងទើបតែចេញពីប៉ុលពតមក គឺថាអត់មានអ្វីទាំងអស់គ្នាហើយ
មានតែស្លៀកសម្លៀកបំពាក់ធម្មតា មិនមានមង្គលការណាអោយធំនឹងគេទេ។
ត្រាន់តែផ្កាមួយបាច់មក អង្ករមួយប៉ែដាំចែកគ្នាហូបពេញមួយក្រសួង
រៀបចំទាំងអស់គ្នាការចឹងតែម្តងទៅ ក្នុងពិធីហ្នឹងណាអូនការចប់ឆ្នាំ៧៩តែម្តង។
ពួកយើងធ្វើការបានមួយឆ្នាំក៏រៀបការទៅ ដល់ពេលរៀបការបាន៤ឆ្នាំ
គេក៏អោយអ៊ុទៅរៀនបញ្ញលប្រៃសណីយ៏។ ហើយគាត់ចូលមក
គាត់បានធ្វើជាចៅហ្វាយខេត្តកំពង់ចាម ធ្វើបាន៤ឆ្នាំទើបតា ព្រាប ប្រដៃ
ចូលគេតែងតាំងគាត់ចូលឆ្នាំ៨០គត់ ប្រធានខេត្តកំពង់ចាម។
រួចបានក៏បានតំណែងតៗពីគាត់មកទៀតមក បានតែ២ឆ្នាំ ដោយសារកាប៉ាស៊ុតេគាត់នៅទាប
និយាយអោយចំកាប៉ាស៊ុតេអ៊ុបានត្រឹមមើលអក្សរបានទេ។ ចឹងកាប៉ាស៊ុតេគាត់
កាលមួយជំនាន់តា ហ៊ុន ណេងនឹង គេចង់ស្ទួចគាត់ឡើងដែល ប៉ុន្តែគាត់មានកំរិតទាបពេក
គាត់ជាកូនអ្នកស្រែចំការអ្នកព្រៃវែងណាអូន។ ដល់ពេលដែលចប់សង្គ្រាម
គាត់ក៏មានប្រវត្តិតស៊ូរបស់គាត់ គាត់ក៏ជាប់ទៅតាមប្រវត្តិតស៊ូរបស់គាត
កាលនៅជំនាន់នោះគេមិនទាន់រើសកាប៉ាស៊ុតេ ទាបឬខ្ពស់ទេ។ ដល់បានពាឆ្នាំមក

យើងមានអ្នកចេះដឹងច្រើន គេក៏ដកគាត់ចេញអោយមកធ្វើជាប្រធានគមនាគមន៍ខេត្តទៅ
និងជារឿងរបស់គាត់។ តាហ៊ុន ណេង នៅជំនាន់នោះ ចង់យកគាត់ធ្វើការងារជាមួយ
តែដោយសារគាត់មានកំរិតទាបទៅវាមិនរួច ពីព្រោះគាត់រត់ លូនជាមួយគ្នា ហ៊ុន ណេង ហ៊ុន
សែនអីហ្នឹង។

ក៖ ចឹងតលូវអ៊ុំប្រុស គាត់នៅណាដែរ?

ខ៖ គាត់បានចែកឋានបាត់ហើយ គាត់បានចែកឋានទៅ៤ឆ្នាំហើយ។

ក៖ ចឹងបើពួកអ្នកដឹកនាំខេត្តអី ឃើញអ៊ុំពួកគាត់ស្គាល់អ៊ុំដែរទេ?

ខ៖ ពួកគេស្គាល់អ៊ុំតើ ឧស្សាហ៍ទៅលេងដែល ទៅលេង គុណ គីមអី ជាមួយមិត្តភក្តិគាត់ចាស់ៗ
ដែលគាត់ធ្លាប់បានទៅទំនាក់ទំនងជាមួយមេភូមិ។ ប៉ុន្តែការទៅលេងយើងមានភាពស្តួចស្តើច
ដោយសារយើងមានកំរិតទាប ការចូលទៅតលូវមានរនាំង ទ្វារបិទ រនាំងបើក
ចឹងវាពិបាកដើម្បីយើងទៅសួរសុខទុក្ខ។ ការទោរបស់គាត់ដូចជាស្តើច
លុះត្រាទាល់តែគេជួបគាត់ដោយចៃដន្យ ឬមួយក៏គេមកលេងខេត្តកំពង់ចាមអីចឹងទៅ
ទើបគេបានមកលេងអោបក្រសោបគាត់។ បើថាអោយដូចជាពីជំនាន់ប៉ុលពត
គឺថាអត់ទេការងារតលូវស្តើចហើយរៀងៗខ្លួននោះ គាត់មិនតូចចិត្តរឿងអស់នឹងនោះ។

ក៖ ហើយចឹង ដល់ពេលដែលអ៊ុំបានរៀបអាពាហ៍ពិពាហ៍ តើអ៊ុំធ្វើយ៉ាងដូចម្តេច
បានជាអ៊ុំសម្រេចចិត្តរៀបការជាមួយនឹងគាត់?

ខ៖ អ៊ុំគិតថា ដូចជាមើលចិត្តថ្លើមគាត់ទៅ យើងអាចរួមរស់នៅជាមួយគាត់បាន
ហើយគាត់បានគ្រប់យ៉ាង គាត់មិនចេះផឹក គាត់មិនចេះស៊ី ការងាររបស់គាត់ល្អណាស់
ហើយយើងមើលអត្តចរិតតែប៉ុណ្ណឹងទេ។ អត់មានគិតថាមានក្រអីទេ
ក្រចុះអោយតែមានគ្រប់យ៉ាងនឹងឯង ទ្រព្យសម្បត្តិអ៊ុំមិនខ្វល់។

ក៖ ចុះសំរាប់អ៊ុំ តាំងពីការជាមួយអ៊ុំប្រុសមក តើអ៊ុំមានកូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានកូនតែ៣នាក់ទេ។

ក៖ អ៊ុំអាចជួយប្រាប់ឈ្មោះរបស់ពួកគាត់បន្តិចបានដែរទេ?

ខ៖ ឈិន ស្រីឡែន កើតនៅឆ្នាំ១៩៨៧ គេការហើយ បានមក ដួង ដារ៉ានេះ ដូចជាឆ្នាំ១៩៩៣
ហើយបានមកមករា មានតែ៣នឹងទេ។

ក៖ ចឹងរាល់ថ្ងៃ កូនរបស់អ៊ុំរស់នៅជាមួយនឹងគ្នា ឬមួយក៏បែកគ្នាដែរ?

ខ៖ រាល់ថ្ងៃរស់នៅជុំគ្នាទាំងអស់។

ក៖ កូនច្បងមានក្រុមគ្រួសារហើយ ចុះកូនទី២?

ខ៖ នៅ ដួង និងមករា។

ក៖ ចឹងនៅកូនកណ្តាល និងកូនពៅ។ ចុះសំរាប់អ៊ុំវិញ តើអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានបងប្អូន៧នាក់ បងប្អូនរបស់អ៊ុំបង្កើតទាំងអស់៧នាក់។

ក៖ តើអ៊ុំអាចជួយរៀបរាប់ឈ្មោះរបស់ពួកគាត់ទាំងអស់បានដែរទេ?

ខ៖ ចាស! ឈ្មោះ ព្រាប ឪវ៉ា គេស្លាប់នៅជំនាន់ប៉ុលពត រួចមក ព្រាប សួគ៌ា
គេស្លាប់នៅជំនាន់ប៉ុលពតដែល។ មកអ៊ុំ ព្រាប សូរិយា បានមកទៀត ព្រាប ដានិន
បានបន្ទាប់មកទៀត ព្រាប បែនសុម៉ាឡា ប្រធានម៉ាស៊ីនទិព្វខេត្តកំពង់ចាម
បានមកប្អូនពៅអ្នកគ្រូ ព្រាប សូដានីនឹង ជាគ្រូសាលាលីសេខេត្តកំពង់ចាម បង្រៀនថ្នាក់ទី១២។

ក៖ បងប្អូនរបស់អ៊ុំ ជាអ្នកធ្វើការនៅខាងក្រសួង និងមន្ទីរទាំងអស់។

ខ៖ ចាស! ជីតារបស់ខ្ញុំជាសាលាដំបូងខេត្តកំពង់ចាម ហើយជាមេធាវី
ហើយដល់ពេលប៉ារបស់ខ្ញុំទៀត គាត់គឺជាគ្រូបង្រៀន Professor នៅខេត្តកំពង់ចាម
សាលាសីហនុនឹងដែល។ សុទ្ធតែមានប្រវត្តិជាអ្នកធ្វើការ
បានចឹងនៅជំនាន់ប៉ុលពតគេមិនទុកយើង គេរៃចោលទាំងអស់ អ្នកធ្វើការដូចជាគ្រូបង្រៀន
សូម្បីតែគាខ្ញុំសាលាដំបូងក៏ត្រូវគេសម្លាប់ចោលដែល។

ក៖ ចុះសំរាប់អ៊ុំ តើគេមានសួរអ្វីអំពីអ៊ុំថា អ៊ុំពីមុនមានធ្វើការងារអីចឹងទេ?

ខ៖ ជំនាន់នោះ អ៊ុំនិយាយអោយចំគីយើងធ្វើមិនចេះតែម្តង សូម្បីតែអក្សរក៏មើលបានតិចតួច
តែមកដល់ជំនាន់ប៉ុលពត វាតែងតាំងអោយធ្វើជាគ្រូកុមារ គ្រូចាស់ អោយតែចេះ ក ខ គ
គេអោយយើងបង្រៀនហើយនៅជំនាន់ប៉ុលពត។ គេមិនទុកអោយយើងនៅស្រួលទេ
គេដាក់យើងនិយាយទៅ យើងអត់ចេះតែម្តង ដោយសារជីតាគេយកទៅសម្លាប់ចោល
ឪពុកគេសម្លាប់ចោល ម្តាយគេសម្លាប់ចោល អោយតែថាអ្នកធ្វើការគេមិនទុក។
ចឹងយើងក៏ថាមិនចេះតែម្តងទៅ អោយគេមើលមកយើងថា អាន អក្សរ ក
ដាច់ក៏ចេះតែនៅនឹងគេដែលទៅណា ត្រូវតែធ្វើចឹងចេះតែធ្វើតាមគេទៅ។

ក៖ ចុះសំរាប់ ឪពុកម្តាយរបស់អ៊ុំវិញ តើអ៊ុំនៅចាំអំពីឈ្មោះរបស់ពួកគាត់
និងអាយុរបស់ពួកគាត់ដែរទេ?

ខ៖ ឪពុករបស់ខ្ញុំឈ្មោះ ព្រាប បែន គាត់កើតនៅឆ្នាំ១៩១៥ ឯម្តាយរបស់ខ្ញុំកើតនៅឆ្នាំ១៩២១។
កំនើតរបស់គាត់ម្តាយខ្ញុំជាអ្នកនៅកំពង់ចាម ឪពុកខ្ញុំនៅសៀមរាប។

ក៖ ម្តាយរបស់អ៊ុំ មានឈ្មោះអ្វីដែរ?

ខ៖ គាត់មានឈ្មោះ ម៉ា ណៃគៀវ គាត់គឺជាគ្រូនាយិកាបង្រៀនថ្នាក់ទី១០
ថ្នាក់លីសេដែលម៉ាក់ខ្ញុំនោះ។

ក៖ ហេតុអ្វីបានជាលោកអ៊ុំស្រី និងលោកអ៊ុំប្រុសបានជួបគ្នា?

ខ៖ និយាយអោយចំទៅ ខ្ញុំកើតអត់ទាន់ពួកគាត់ផង បានដឹងថាប៉ាម៉ាក់យើងធ្វើអីខ្លះ
ល្អហើយ។

ក៖ ជូនកាល គាត់បានប្រាប់អ៊ុំថា។

ខ៖ អាចនិយាយលម្អិតចឹង ចឹងខ្ញុំនិយាយថាម្តាយឪពុករបស់ខ្ញុំ ជាជនជាតិថៃសុទ្ធ ម្តាយខ្មែរសុទ្ធ
ឪពុកថៃ។ កងទ័ពគេវៃគ្នានៅសៀមរាប ថៃនឹងត្រូវគ្រាប់ក៏រត់មកសុំម៉ាខ្ញុំនៅជាមួយ
ត្រូវគ្រាប់នៅហ្នឹងជើង គាត់នៅព្យាបាលជនជាតិថៃនឹង។ ដោយសារការព្យាបាលរាប់ខែ

រាប់ឆ្នាំក៏ធ្វើអោយម៉ាខ្ញុំស្រលាញ្ជាមួយជនជាតិថៃហ្នឹងទៅ។ ចឹងឪពុកម្តាយរបស់គាត់
ម្នាក់ថៃម្នាក់ខ្មែរ គាត់នៅទល់ដែនថៃណាអូន ហើយមកដល់ជំនាន់ប៉ាខ្ញុំ
គាតើមើលឃើញម៉ាក់របស់ខ្ញុំ ដោយសារបងស្រីរបស់គាត់រកស៊ីលក់ពេជ្ឈ និងទាំងគ្រាប់។
ចឹងគាត់ដើរលក់ពេជ្ឈទាំងគ្រាប់ គាត់លក់រកតែនាម៉ឺនមន្ត្រីទេ គាត់មិនរកតែទេអ្នកក្រីក្រ
គាត់រកដូចជាតុលាការ តាខ្ញុំជាសាលាដំបូង
ចឹងគាត់មកទាក់ទងលក់ពេជ្ឈទាំងគ្រាប់ហ្នឹងហើយ ដោយសារពួកនោះមានលុយទិញ
គាត់មិនដើរលក់តាមជនបទទេ។ នឹងដោយសារម៉ាគៀរខ្ញុំស្រលាញ់តាបែន
ដោយសារបងស្រីជាអ្នកដើរលក់ នឹកឃើញថាគ្រួសារក្រឡាបញ្ជីម៉ាគៀរ មានកូនស្រីតែមួយ
ហើយគាត់ក៏មានកូនតែមួយដែល ជីតាខ្ញុំមានកូនតែមួយទេ។
កេរ្តិ៍អាករជំនាន់ប៉ុលពតត្រលប់មកវិញ គេយកបាត់អស់ហើយ
អត់សល់អត់ទេមកវិញបាតដៃទទេតែម្តង។ ពីព្រោះយើងជាស្រី
ស្ត្រីមេម៉ាយមានបងប្អូន៧នាក់ជាបន្តក មានស្រីច្រើនប្រុសតិចមានប្រុសតែ២នាក់ទេ
ចឹងការរស់នៅដំបូងមក មិនអាចគ្រប់គ្រងនៅខេត្តបាន
ដោយសារជំនាន់នោះមានវៀតណាមមានអីច្រើន។ កំកូនៗទៅស៊ីឈ្នួលគេនៅតាមចំការ
នៅតាមមាត់ទន្លេ ចឹងយើងមិនហ៊ាននៅទៀត ពីព្រោះយើងខ្លាច មានសម័យនឹងគទៅទៀត
ខ្លាចអ្នកមានការងារត្រូវគេរៃចោល។ ដល់ចឹងទៅ អត់ហ៊ាននៅទេរត់ទៅនៅចំការ
ស៊ីឈ្នួលកាច់ពោត កាច់អីអោយគេអោយតែរស់សិនទៅ។ ដល់ពេលយើងត្រលប់មកវិញ
គេយកដីចំការនៅទីរួមខេត្តរបស់យើងអស់ហើយ
ដីអ៊ុំមានច្រើនកន្លែងណាស់នៅកំពង់ចាមនោះ ដល់ពេលត្រលប់មកវិញ២ឆ្នាំ, ៣ឆ្នាំនឹង
គេយកអស់ហើយ។

ក៖ ចឹងដល់អ៊ុំត្រលប់មកវិញ អ៊ុំអត់អាចចាប់យកកន្លែងផ្សេងៗទៀតបានទេ?

ខ៖ អ៊ុំនិយាយអោយចំ ពេលចេញត្រលប់មកវិញអត់មានបានចាប់យកអីទេ
មានតែម៉ាក់ហើយមានតែអ៊ុំ ដោយសារកូនបងៗស្លាប់អស់ហើយ។ នៅសល់តែម្នាក់ឯង
ចឹងឃុំក្រែងប្អូនៗទាំង៧នាក់នឹង អ៊ុំរកស៊ីលក់តាមចិញ្ចើមថ្នល់ អ៊ុំរកស៊ីជួនពោត
ដើម្បីផ្តល់ការងារអោយប្អូនម្នាក់ អោយវារៀនបាន៣ឆ្នាំម្នាក់ធ្វើជាគ្រូបង្រៀនបាន។
ប្អូនប្រុសធ្វើការនៅកន្លែងម៉ាស៊ីនទឹក ជួយប្អូនអោយទៅប្រទេសអាល្លឺម៉ង់បាន៣ឆ្នាំ
ដល់ប្អូនមកក្រោយទៀតធ្វើការនៅរោងចក្រ ដល់ពេលប្អូនបានការងារធ្វើអស់គ្នាចឹងទៅ
ទើបអ៊ុំបានរៀបការ ទាំង៤នាក់នឹងបានការងារ។

ក៖ ចឹងដូចជាពីមុន មើលទៅអ៊ុំដូចជាអស្ចារ្យណាស់ មកដល់ពីសម័យប៉ុលពតអ៊ុំធ្លាក់ខ្លួន?

ខ៖ ធ្លាក់ខ្លួនគឺមកដោយបាតដៃទទេតែម្តង។

ក៖ បាទ! ចឹងអ៊ុំមានអារម្មណ៍យ៉ាងម៉េចដែរ?

ខ៖ ខ្ញុំមានអារម្មណ៍ថាឈឺចាប់ណាស់ ដែលយើងធ្លាប់តែមានវណ្ណៈមួយគួរអោយ
និយាយទៅកាលនៅជំនាន់លុនណុល និងជំនាន់សីហនុយើងក៏ជា
មនុស្សនៅក្នុងសង្គមជាមួយគេដែរ។ មកដល់ចប់ទៅ យើងអស់អត់មានអីសោះ
មានតែម៉ែមួយនិងកូន៧នាក់ សូម្បីតែម្តាយមីង
ម្តាយអ៊ុំនិយាយអោយចំអ៊ុំគ្មានសាច់ញាតិតែម្តង។ ស្លាប់ទាំងអស់ ពីព្រោះក្រុមគ្រួសាររបស់អ៊ុំ
ជាគ្រួសារមួយដែលធ្វើការងារ គេរៃចោលទាំងអស់
នៅពេលដែលការកូនមានតែម្តាយមួយនឹងទេ
បើអស់ម្តាយមានតែម៉ាវាទេអង្គុយនៅក្បាលកន្ទេលអោយ។ អត់មានអ្នកណាទេ
មានតែលើកដៃទាំង១០សំពះញាតិទាំង៧សន្តាន អោយមកជួយយើងតែប៉ុណ្ណឹង ការកូនក្តី
ការប្អូនៗក្តីមានតែអ៊ុំមួយទេ ដែលទៅអង្គុយនឹងនោះ។ គេសួររកអ៊ុំ រកមីងម៉ាអី

អ៊ុំមានបងប្អូន៥, ៦នាក់តែស្លាប់ទាំងអស់ ចេញមកវិញគឺថាចប់សូម្បីតែដីមួយម៉ែត្រ
ក៏អ៊ុំអត់មានដែល។ យើងមកទាន់គេតើ តែនិយាយទៅយើងជាក្មេងក្រមុំ
ជំនាន់នោះអ៊ុំចេញមកអាយុ២២, ២៣, ២៤ឆ្នាំហើយ ជាមនុស្សមួយជាមេគ្រួសារហើយ
ពីព្រោះម្តាយរបស់អ៊ុំរាងជរា។ ចឹងឃុំគ្រងប្អូនទាំង៧នាក់នឹងណា
អោយពួកវាមានការងារចឹងទៅ។

ក៖ ចឹងអ៊ុំ ខ្ញុំចង់សួរអំពីជីវប្រវត្តិរបស់អ៊ុំវិញ សំរាប់អ៊ុំពីតូចរហូតមកដល់ធំ ពីមុនសម័យប៉ុលពត
តើអ៊ុំធ្វើអ្វីខ្លះដែរ?

ខ៖ ពីមុនប៉ុលពត ឬជំនាន់លុននុល?

ក៖ ជំនាន់លុននុលវិញ?

ខ៖ ពីមុនជំនាន់លុននុលជំនាន់៧៥ អ៊ុំជាក្មេងទំនើសមួយ
ពីព្រោះជាទម្លាប់មួយថាឪពុកជាគ្រូបង្រៀន ម្តាយជាគ្រូបង្រៀន ជីតាជាតុលាការ។
និយាយអោយចំមានឡានជិះ តាំងពីកើតមកតែម្តង និយាយរួមខ្ញុំអត់ដែលបានបើកទេ
តែយើងមានអ្នកបំរើបើកអោយ។ ដូចថាកូនគាត់៧នាក់ ក៏អោយមានអ្នកបំរើ៧នាក់ដែល
ចឹងការទៅរៀនរបស់យើង ជាក្មេងដែលទំនើសមួយ ការពិតទំនើសច្រើននៅជំនាន់លុននុល។
ទម្រាំតែយើងប្រលងដល់ថ្នាក់ទី៣ កាលជំនាន់នោះគេហៅពួកប្រលង class second ហើយ
ចឹងអ៊ុំអត់មានការលំបាកទេ ដោយសារឪពុកក៏ជាគ្រូ ម្តាយក៏ជាគ្រូ។ ជីតាក៏ជាតុលាការ
និយាយអោយចំ គ្រួសាររបស់អ៊ុំនៅជំនាន់នោះ ក៏ជាគ្រួសារមន្ត្រីមួយដែល
ជំនាន់សក្តិភូមិរហូតមកដល់ជំនាន់ប៉ុលពតនេះ គឺអ៊ុំចប់តែម្តង។

ក៖ ចឹង កាលនៅជំនាន់នោះ ម៉េចក៏អ៊ុំមិនរត់ទៅក្រៅប្រទេសទៅអ៊ុំ?

ខ៖ អ៊ុំអត់ដែលបានទៅ បានតែប្អូនប្រុសមួយគេបានទៅ ចំពោះអ៊ុំអត់បានទៅ
អត់បានទៅទេនៅតែក្នុងស្រុកខ្មែរ រីយើងនៅតូចដែលកាលនោះ ១៤,
១៥ឆ្នាំអីអត់ទាន់បានទៅទេ។ បើប៉ាបានទៅអាមេរិច តាបែនរបស់ខ្ញុំធ្លាប់ទៅអាមេរិច។

ក៖ ចុះម្តាយរបស់អ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំអត់បានទេ គាត់ជាប់បង្រៀននៅសាលាលីសេនឹង។

ក៖ ចឹងគាត់ធ្លាប់បានទៅប្រទេសណាខ្លះដែរអ៊ុំ?

ខ៖ គាត់ធ្លាប់បានទៅប្រទេសអាមេរិចប្រហែលជាបាន អត់ទេកាលគាត់បានទៅខ្ញុំនៅតូចដែល
ចាំតែដល់ខ្ញុំអាយុ១០ឆ្នាំគាត់បានវិលមកវិញ។

ក៖ ចឹងអ៊ុំអាចជួយប្រាប់អំពីជីវប្រវត្តិរបស់អ៊ុំ កាលពីនៅក្នុងសម័យប៉ុលពត? តើអ៊ុំនៅទីណា?
ហើយអ៊ុំមានបានធ្វើអ្វីខ្លះ?

ខ៖ សម័យប៉ុលពត អ៊ុំទៅរស់នៅជំនាន់នោះ និយាយអោយចំ
អ៊ុំអត់បានទៅរស់នៅជាមួយម្តាយ។ កាលនៅជំនាន់នោះអ៊ុំមានអាយុ១៥ឆ្នាំ
គេយកអ៊ុំទៅដាក់នៅការដ្ឋាននារីតំបន់ ចឹងយើងអត់មានបានជួបមុខម្តាយទេ
អស់រយៈពេល២ឆ្នាំ ៨ខែនឹងគឺយើងបែកពីគាត់។ នៅក្នុងការរស់នៅជំនាន់នោះ
អ៊ុំសុខចិត្តអត់ផ្តត់ ម្តាយគេអោយដើរ៥០គីឡូដីនៅតំបន់សហករ ឯយើងនៅការដ្ឋានសម័យ។
នៅពេលយប់ឡើងអ៊ុំធ្វើការការដ្ឋានសម័យ អ៊ុំនៅទៅសង្គ្រោះម្តាយបាន

ពីព្រោះយើងរឹតអង្ករម្នាក់មួយស្លាបព្រាម្នាក់ ចឹងទៅការដ្ឋានសម័យនឹង
ពេលណាយើងធ្វើម៉ោងពារហូតដល់ភ្លឺ រហូតដល់ម៉ោង៨យប់ទើបគេអោយយើងសំរាក។
កាលពីអ៊ុសំរាកម៉ោង៨យប់ អ៊ុដើរកាត់ព្រៃភ្នំពីការដ្ឋានសម័យ៥០០គីឡូដ៏ណាក្បួយ
ដើរកាត់ព្រៃភ្នំដើម្បីខ្ចប់អង្ករ ខ្ចប់ដូចជា រកតាំងពីកង្កែប ក្តាម ខ្មៅ ខ្យង
រឹតខ្ចប់ទៅរកប្អូនទាំង៧នាក់ ដែលនៅជាមួយម្តាយជំនាន់ប៉ុលពតនឹងទៅអោយគាត់។ ជូនណា
អ៊ុទៅអង្គុយនៅក្រោយដើមស្នោត គេដេកតែអ៊ុអត់ដែលដេកទេ
មួយយប់ទល់ភ្លឺគឺអ៊ុអត់ចេះដេកយប់ទេ ថ្ងៃក៏ដោយម៉ោង៧យប់អ៊ុទៅអង្គុយក្រោយដើមស្នោត
ឃើញខ្យល់ផ្លាក់មកខ្លាំងៗ អង្គុយចំដើមស្នោតណាមានផ្លែទុំ ក៏ផ្លាក់មកចំមនុស្ស១០នាក់។
ហើយបានមួយគ្រាប់ចែកគ្នាមិនឈ្នះ យើងចែកគ្នាញ៉ាំម្នាក់តិច ក៏ចេះតែចែកគ្នាអ្នកនោះតិច
អ្នកនេះតិចទៅ ចែកគ្នាញ៉ាំស្នោតនៅចឹងទៅ។ នឹងនៅពេលដែលមានស្នោតទុំ
ដល់ផុតខែស្នោតទុំយប់ឡើងអ៊ុ មេៗគេជប់បារីនឹងណា យើងទៅអង្គុយជិតគេ
គេបោះកន្ទុយបារីយើងក៏យកជើងញីៗគៀរទុក។ មួយកាបៅ២០កន្ទុយចឹងទៅ
ដាក់ក្នងកាបៅចឹងទៅយើងចេញពី កន្លែងរើសបារីពីម៉ោងមួយ យើងដើរកម្តាយហើយ។
យប់ឡើងខ្លាំងដើរកាត់ភូមិជួបខ្លា ជួបអីដែលតើអូន តែទៅដល់ជំរុំគេរៃមនុស្សចោលទៀតណោះ
ពួនឡើងភ័យគេរៃរួច ក៏រៀនចេញពីគេទៅទៀត។ ទៅរកតាមួយនៅខាងសហករ
និយាយអោយចំគាត់ជា អ្នករកចំណីអាហារដាក់អ្នកសហករ រួចអ៊ុក៏ទៅរកគាត់។
រួចយានឯងទៅខាងណា ខ្លាំមករកម៉ែនឹងណា មករកដូរអង្ករ ដូរត្រីអោយម៉ែ
ចឹងបានប៉ុន្មានហើយនឹង។ ខ្លាំក៏យកកន្ទុយបារីបានដាក់នៅលើស្មៅអោយគេទៅ គេជាអ្នករាប់
គេសួរថាស្រលាញ្ចអីគេខ្លះមើលទៅ ខ្លាំថាស្រលាញ្ចកង្កែបនេះ ចឹងតថ្លែជាមួយកន្ទុយបារីនឹង
រាប់៥ទៅគេក៏ដាក់៥អោយយើងក៏បានកង្កែបមួយ។ ហើយយើងបានត្រីធំ អាមួយនេះ២០
ចឹងតែនៅតថ្លៃគ្នាដោយប្រើពាក្យកន្ទុយបារី ដូរយកអាហារមកហូប
ដល់អស់កន្ទុយបារីពីហោបៅទៅ។ ខ្លាំក៏ដើរចេញពីគេទៅ គេសុំភ្ជួរនឹងដុតអាំង
ហើយអត់មកការដ្ឋានវិញទេ សំដៅមកម្តាយម៉ោង៥ហើយ ចែកពួកប្អូនៗដែលនៅកុមារនឹង
អោយញ៉ាំម្នាក់តិចៗ។ ហើយបើអ៊ុធ្វើការនៅការដ្ឋានពេលថ្ងៃ អ៊ុដើរដកស្លាបទា
ទៅគស់ឫសល្ហុរចឹងណាអូន បានរឹតៗចឹងមកជាមួយអង្ករមួយកំប៉ុង
ប្រហែលជា២០គ្រាប់ទេជាមួយបបរ ដាក់នៅក្នងក្រឡោបដូងចឹងទៅ។ ខ្ចប់ជាមួយក្រម៉ាចឹងទៅ
ដុតនៅក្នងនឹងទៅ យកទឹកមកកូរៗទៅ បបរនឹងខ្ចប់យកទៅអោយម្តាយ
និងហើយគេបបរសាមជប់យើង។ អាចអោយប្អូននិងម្តាយទាំង៧រស់ចេញមករិញបាន
យ៉ាប់នៅជំនាន់ប៉ុលពតអ្នកណាក៏យ៉ាប់ដែលក្បួយ។

ក៖ អត់ទេអ៊ុ ឃើញអ៊ុដើរពីកន្លែងធ្វើការ ទៅផ្ទះរបស់ម្តាយអ៊ុ អ៊ុអត់ខ្លាចគេវៃ
អត់ខ្លាចគេចាប់ទេ?

ខ៖ និយាយអោយចំ នៅជំនាន់នោះអត់ខ្លាចទេ យប់ឡើងនៅពេលដែលយើងជិតចប់នេះ
និយាយទៅគេអោយអ៊ុទៅយកទ័ព ដែលត្រូវគ្រាប់ត្រូវអី។ គេអោយអ៊ុទៅយកនៅតាមរ៉ាថភ្លើង
ទៅយក២នាក់ចឹងទៅ ពីមួយស្នែកទៅមួយស្នែកមានចំងាយ១គីឡូដ៏
យើងទាំង២នាក់ក៏សែងតែយើងហ៊ានដាក់ដល់ដី គេសម្លាប់យើងចោល។
មានអ្នករបួសផ្លាយពោះរៀន ផ្លាយអីចឹងណា យើងចាប់ដាក់នៅក្នងអង្រឹងចឹងណា
និយាយអោយចំយើងជានារីការដ្ឋានតំបន់។ គេហៅភូមិភាគនៅជំនាន់នោះ
សែងចឹងទៅបើគេបាញ់ទម្លាក់គ្រាប់មកទៅ យើងក៏រត់ទៅពួនសិនទៅ
ហើយយើងរត់មិនទាន់ពួកអ្នកដែលត្រូវរបួសទៀតណា
ពួកអស់នឹងរត់លឿនជាងយើងទៅទៀត។ ពួករារត់ទៅពួនបាត់អស់ហើយ
ដល់ពេលសែងហត់ពេកក៏រត់ទៅតែម្តងទៅ និយាយទៅអាចដែល
ដូចឃើញវាជិតស្លាប់យើងក៏អោយទឹក ហើយវាក៏ស្លាប់បាត់ទៅ។ យកទៅដាក់អោយគេចឹងទៅ
ក៏មានគេជាអ្នកយកតទៀតចឹងទៅ នៅពេលដែលជិតចប់គេយកខ្លាំទៅជួរនារីប៉ុលពត
ធ្វើជាទាហានស្រីតែម្តង គេដូរយើងពីការដ្ឋានសម័យមកដាក់នៅទីនេះតែម្តង។

ហើយនៅឆ្លៀតឱកាសរកខ្លួនឯង យើងញុំមិនគ្រាន់តែអង្ករមួយស្លាបព្រានោះ
នៅខំយកស្លាបទាមួយរិចយកទៅលាយញុំ។

ក៖ ចឹងកាលនៅសម័យនោះ អ៊ុំនៅកន្លែងណាដែរ?

ខ៖ កាលនោះ អ៊ុំនៅខេត្តកំពង់ឆ្នាំង ស្រុកប្រមាស ចឹងពិនឹងចប់ទៅគេយកអ៊ុំទៅដាក់ក្នុងគុក
ពួកអ្នកធ្វើការ ពួកធ្វើជាមន្ត្រីនឹងគេឃុំទុករយៈ៧ខែ ក៏មកនៅកន្លែងសហករ។
ជាការលំបាកច្រើន បើប៉ាអ៊ុំតែរៃចោលដោយសារគាត់ទៅលួចដំលូងគេញុំ
គាត់ឃ្លានពេកគាត់ទ្រាំមិនបាន ដូចជាដំលូងដែលយើងយកហើយ
វានៅសល់ក្នុងនោះវាមានដុះឫសតិចតួច។ គាត់ក៏ទៅខ្ទេះយកមកញុំ
ដល់ពេលចឹងទៅគេចាប់បាន គេថាយើងនឹងជាចោរ គេក៏យកគាត់ទៅរៃបាត់នឹងខ្ទិតអស់
ទៅយកឆែកខែមករ៉ុំម្រាមដៃ ដែលគេបែកទាំងសងខាង។
គេយកបាតដៃយើងដាក់នៅលើគល់ឈើ ហើយគេយកញញួរមករៃកំតិចបាតដៃទាំង២នឹងទៅ
អ៊ុំថែឪពុកដែលពិការនឹងបាន១ឆ្នាំជាង ទើបបានគាត់ខ្ចីដែល។ គេរៃធ្វើបាបគាត់ណាស់
គេរៃតែម្តងមិនមែនស្លាប់ ដោយសារគេកាត់ម្រាមដៃទេ
និយាយអោយចំគេយកញញួរមករៃកំទិចចោលម្រាម។

ក៖ ចុះអ៊ុំ បន្ទាប់ពីចប់សម័យប៉ុលពត តើមករស់នៅកន្លែងណាវិញដែរ?

ខ៖ ចប់ពីប៉ុលពតអ៊ុំចូលមកខេត្តកំពង់ចាមនឹងវិញ នៅសល់ម្តាយមែម៉ាយមួយ
និងប្អូន៥នាក់ស្លាប់អស់២នាក់ហើយ ចឹងអ៊ុំជាមេគ្រួសារតាំងពីឆ្នាំ៧៩មកតែម្តង។

ក៖ ហើយនៅពេលដែលអ៊ុំការហើយ នៅតែពិបាកទៀតទេ ឬមួយក៏ធូរដែរ?

ខ៖ ការហើយអ៊ុំអត់ពិបាកទេ ដោយសារតាគាត់ជាប្រធានគមនាគមន៍ ផ្តល់លុយដល់អ៊ុំបាន៤
១០តំលើងដែរ។ ការហើយគាត់មានឡាន មាន Land Rover អាឡានកាម៉ាសពា
ហើយជាមួយគាត់មានលុយណាស់ ពីព្រោះអីចប់មកគេត្រូវការអ្នកធ្វើការណាស់
មិនក្រទេការហើយអ៊ុំក៏មាន។

ក៖ ហើយបន្ទាប់មក កូនៗកើតមកទាន់ពេលដែលអ៊ុំមានដែរទេ?

ខ៖ ទាន់ ទាន់ដល់រហូតអ៊ុំមាន ៤ខ្នង ២ជាន់អោយកូននៅ។

ក៖ ហេតុអ្វីបានជាអ៊ុំដូរពីទីនោះ មករស់នៅទីនេះវិញ?

ខ៖ មកពីខាងបងប្អូនខាងប៉ា គេទាមទារថាទ្រព្យសម្បត្តិនឹងជាដីភូមិ
ដីចំការខាងឪពុកគេណាណី គេទាមទារមកសុំលក់គ្រប់កន្លែង។ ការជាមួយគាត់
បើនិយាយតាមការពិតអាយុគាត់ជាចាស់ ពីមុនគាត់មានប្រពន្ធមួយហើយ
ដល់ចឹងគាត់មានកូនក្នុងបន្ទុក កូន៤នាក់នៅក្នុងបន្ទុករបស់គាត់។ ហើយនោះ
នៅក្នុងដំនាន់នោះកាលអ៊ុំការនៅឆ្នាំ៨៣នោះ
កូនគាត់ដែលតូចជាងគេមានអាយុ៧ឆ្នាំដែលហើយ ដល់ធំៗអាយុ៣០ជាងឆ្នាំហើយ។
គាត់ជាបុរសពោះម៉ា ហើយប្រពន្ធគាត់ស្លាប់ដោយសារ គ្រោះថ្នាក់ចរាចរណ៍
ដល់ចឹងទៅកាលអ៊ុំធ្វើផ្ទះនៅនាគព័ន្ធនឹង កូនចៅវាថាជាកេរ្តិ៍របស់ឪពុកម្តាយរបស់គេ។
អ៊ុំក៏លក់តទៅ លក់បាន៣ម៉ឺនជាង ក៏ចែកកូនចៅមុនៗ ម្នាក់៥ពាន់ជាងទៅ
ហើយអ៊ុំទុកបន្តកខ្លួនឯង១ម៉ឺនដុល្លារសំរាប់កូនក្រោយ៣នាក់។
នេះជាកម្លាំងញើសឈាមរកមកទៀតទេ លុយលក់ពីមុនអស់ហើយ
បាន៣ម៉ឺនចែកកូន៥នាក់អស់ហើយ ទុកមួយម៉ឺនហើយនេះជាលុយកូនក្រោយ

គេខំរកស៊ីខ្លួនគេទេ បានតិចច្រើនដោយខ្លួនគេទេ។ ហើយអត់មានថា
មួយណាជាកេរ្តឺម្តាយចែកអោយ ឬជាកេរ្តឺឱពុកចែកអោយទេ គឺអត់មានទេ។

ក៖ ចឹងអ៊ុ សំរាប់ជីវិតរបស់អ៊ុវិញ តើអ៊ុគិតថាជីវិតពីមុន និងមកដល់សម័យឥឡូវ
មានភាពខុសគ្នាយ៉ាងម៉េចដែរ?

ខ៖ ខ្ញុំគិតថាសម័យលុននុល ជាសម័យត្រេតត្រអាល ដល់សម័យប៉ុលពតគេហៅថាជា
សម័យជូរចត់ មកដល់សង្គមឥឡូវគេថាមិនក្តៅ មិនត្រជាក់
គឺថាអាចរស់នៅបានសុខស្រួលតាមសង្គមបាន។

ក៖ ដោយសារពីមុនគាត់ធ្លាប់មានជីវភាពជាអ្នកមាន ហើយឥឡូវអ៊ុមានជីវភាពដូចចេះវិញ
តើអ៊ុមានអារម្មណ៍យ៉ាងម៉េចដែរ?

ខ៖ កាលដែលខ្ញុំមាននៅជំនាន់លុននុល គឺជាក្មេងទំនើសមួយហើយ កាលនៅជំនាន់ប៉ុលពតជា
ជំនាន់អំណាចផ្តាច់ការ ដល់ចប់សង្រ្គាមនេះមកសម័យនេះ
យើងហៅថាជាសម័យរុងរឿងរបស់យើងហើយ។ បើនិយាយអោយចំក្បាលអ្នកណា
អ្នកនឹងជាអ្នករក បើយើងខ្ជិលគឺដឹងតែអត់ហើយ បើយើងឧស្សហ៍អត់ខ្វះមាន អត់ខ្វះចាយទេ
មានត្រប់របស់ប្រើដែលយើងខំប្រឹងរកនោះ។ យើងកុំទីពឹងអ្នកណាទាំងអស់មកចិញ្ចឹមយើង
សំរាប់ក្រុមគ្រួសារអ៊ុមិនចាំកេរ្តឺរបស់អ្នកណាទេ គឺបណ្តុះកូនមកអោយវាចេះធ្វើ
រកអ្វីដោយខ្លួនឯង។ កុំអាងអឺ ម៉ែលក់កេរ្តឺដី មានមឹងមានអ៊ុនៅឯណាជួយគឺអត់មានទេ
ចឹងកូននៅទឹនេះមុនដំបូង កំសត់ណាស់។ អោយពេលណាមានភ្លៀងមកម្តង
គឺយកចានដែកមកបាំងហើយ ហើយវត្នថាយើញខ្ញុំទទឹកក៏យកចានដែកមកចាំង
យកស្លឹកឈើមកធ្វើជាជញ្ជាំង សូម្បីតែសារិនក៏ស្គាល់ផ្ទះខ្ញុំនៅនាគពីន្ធដែល។ ផ្ទះ
មួយលក់តម្លៃបីម៉ឺនថ្លៃណាស់មិនមែនតូចទេ នៅជំនាន់តាំងពីមកវាអាយុ៨ឆ្នាំ
ហើយអ៊ុតស្លឹតាំងពីបាតដៃទទេ រហូតបានមកនិយាយទៅកំសត់ខ្លាំងណាស់។
បេះស្លឹកឈើដួងជាអ្នកដើរទៅលក់ចឹងទៅ ការរៀនរបស់ដួងក៏នបានតិចតូចដែល
ដោយសារអ៊ុអត់ពេកមិនអាច អោយកូនរៀនសូត្របាន។ ចេះរកស៊ីតាំងពីអាយុ៧ឆ្នាំ
រហូតមកដល់៨ឆ្នាំក៏ជ្របុជទាំងបងប្អូនវានឹង បេះស្លឹកឈើមកអ៊ុវាអោយខ្នុរមក
ក៏ហែកយកទៅលក់ទៀតទៅ រត់ទៅលក់តិចទៅរត់ទៅរៀនតិចទៅ
ដល់បាបលុយក៏រត់មកអោយវិញទៀត។ ទៅរៀនលុយមិនលើសពី២រយទេសំរាប់ដួង
ហើយនិងឡែននោះ បាន៥រយច្រើនពេកហើយដឹងតែអរសប្បាយណាស់
កំសត់មែនតាំងពីលក់ដី។

ក៖ ចឹងខ្ញុំសូមអរគុណច្រើន សំរាប់ថ្ងៃនឹងពិតជាកំសត់មែនទែន។

ខ៖ ចឹងខ្ញុំនិយាយរឿងកំសត់ច្រើនពេក មិនចង់និយាយអោយកូនខ្ញុំ វាឲ្យទេណា។

ក៖ ខ្ញុំសូមអរគុណសំរាប់ឱកាសថ្ងៃនេះ ដែលអ៊ុបានផ្តល់ជាបទពិសោធន៍របស់អ៊ុ
ហើយខ្ញុំដឹងថានឹងអាចជួយអោយកូនអ៊ុបានរៀនច្រើន។ ហើយសំលេងនេះ
ខ្ញុំនឹងយកទៅដាក់នៅក្នុងវេបសាយរបស់សាលា BYU នឹងណាអ៊ុ ចឹងអ៊ុអនុញ្ញាតណោះ?

ខ៖ អ៊ុអនុញ្ញាត អ៊ុអោយយកទៅផ្សព្វផ្សាយ និយាយទៅជាពរជ័យដ៏ធំមួយ
ពីព្រោះអ៊ុមិនអាចនិយាយអំពី ប្រវត្តិទាំងនេះទៅកាន់កូនមិនបានក្បេះក្បាយទេ។
ទោះបីជាកូនរបស់យើងមែន តែយើងមិនអាចនិយាយអោយបានក្បេះក្បាយទេ
ពីព្រោះវាជាការនឿយហត់ អត់ចង់អោយពួកវាឲ្យនូវការលំបាកទាំងនឹងទេ។
ចង់អោយនៅសម័យនេះ កូនតស៊ូឡើង កូនខំប្រឹងឡើង មិនចង់អោយដឹងពីអតីតកាល
វាជារឿងដ៏ជូរចត់មួយ អ្នកណាក៏ដូចជាអ្នកណាដែរ។

កៈ សូមអរគុណសំរាប់ឱកាសថ្ងៃនេះ ដែលអ៊ុំបានផ្តល់ជាបទពិសោធន៍របស់អ៊ុំ។